**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៧៩៤៣ កសក

# សេចក្តីណែនាំ

## អនុវត្តសារាចរណ៍រាជរដ្ឋាភិបាលលេខ ០២ សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

កន្លងមកទោះបីជាច្បាប់ភូមិបាលឆ្នាំ ២០០១ បានកំណត់បញ្ចប់នូវការចូលកាន់កាប់ដីតាមរូបភាពភោគៈហើយក៏ដោយ ក៏មានជនឆ្លៀតឱកាសមួយចំនួនដែលជាឈ្មួញដី ឬ អ្នកមានអំណាច បានចូលកាន់កាប់ដីរដ្ឋដោយអនាធិបតេយ្យតាមរូបភាពផ្សេងៗល្មើសចំពោះនីតិវិធីនៃច្បាប់។ ម្យ៉ាងទៀតដោយដីរដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីកំណត់ទីតាំង និង ព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និង ចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋនៅឡើយ ជាហេតុធ្វើឱ្យស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ច មានការលំបាកក្នុងការគ្រប់គ្រង ទប់ស្កាត់នូវរាល់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់។

ដើម្បីដោះស្រាយបញ្ហាទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងដីធ្លី ជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល បទបញ្ជាលេខ ០១ ប.ប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ ចំពោះមុខនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្នុងគោលបំណងធ្វើការណែនាំនូវនីតិវិធីលំអិតចំពោះស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចក្នុងការទាមទារ ដកហូតយកដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់មកវិញ។

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានពិនិត្យឃើញថា ការអនុវត្តនូវបណ្តានីតិវិធីទាំងឡាយដើម្បីដោះស្រាយបញ្ហារំលោភកាន់កាប់ដីរដ្ឋនៅមូលដ្ឋានពុំទាន់ធានាបាននូវប្រសិទ្ធភាព និង ការទទួលខុសត្រូវរបស់អង្គភាពជំនាញពាក់ព័ន្ធនីមួយៗក្រោមឱវាទក្រសួងនៅឡើយ។ ដូច្នេះដើម្បីជម្រុញការអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមណែនាំ និង ប្រគល់ភារកិច្ចជូនដល់បណ្តាអង្គភាពជំនាញពាក់ព័ន្ធ ដូចខាងក្រោម :

១-គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និង មន្ទីរកសិកម្មខេត្ត ក្រុង ត្រូវក្តាប់ឱ្យជាប់នូវបណ្តាដីរដ្ឋដែលអង្គភាពនីមួយៗមានសមត្ថកិច្ចកាន់កាប់ និង គ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍ :

-ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ

-ដីដែននេសាទទឹកសាប និង សមុទ្រគ្រប់ប្រភេទ ជាពិសេស ដីព្រៃលិចទឹក ដីព្រៃកោងកាង ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល

-ដីជាកម្មសិទ្ធិឯកជនរបស់រដ្ឋផ្សេងទៀតស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង មន្ទីរកសិកម្មខេត្ត ក្រុង ដែលបាន ឬ មិនទាន់បានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឬ បានចុះបញ្ជីដីរដ្ឋក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

២-ចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់លើដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដីព្រៃលិចទឹក ដីព្រៃកោងកាងនិងដីដែននេសាទ ដែលបានធ្វើអត្តសញ្ញាណកម្មមានផែនទីសម្គាល់ផ្លូវការ និង មានអាណត្តិកាន់កាប់ដីច្បាស់លាស់ ដែលច្បាប់បានប្រគល់សិទ្ធិ និង សមត្ថកិច្ចឱ្យធ្វើការគ្រប់គ្រងជាសម្បត្តិសាធារណៈរបស់រដ្ឋ អង្គភាពរដ្ឋបាលព្រៃឈើ អង្គភាពរដ្ឋបាលជលផលមានសមត្ថកិច្ចដែលមានតួនាទីជាអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋនៅមូលដ្ឋាន ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុចទី ៥ នៃសារាចរលេខ ០២ សរ ដែលមានអភិបាលខេត្ត ក្រុង អនុវត្តការចេញដីកាប្រកាសបដិសេធនិងដកហូតដីរដ្ឋនោះមកវិញ ឬ ធ្វើការសម្របសម្រួលជាមួយអ្នកប្តឹងតវ៉ា និង ចាត់ការតាមនីតិវិធី។ ក្នុងករណីអ្នកប្តឹងតវ៉ាមិនឯកភាពតាមសេចក្តីសម្រេចបដិសេធរបស់អភិបាលខេត្តក្រុងលើពាក្យប្តឹងតវ៉ា រដ្ឋបាលព្រៃឈើ ឬ រដ្ឋបាលជលផលត្រូវស្នើមកក្រសួងដើម្បីសុំមេធាវីរាជរដ្ឋាភិបាលប្តឹងអ្នកប្តឹងតវ៉ានោះទៅតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់ជាធរមាន ។

៣-ចំពោះការកាន់កាប់ដោយខុសច្បាប់លើដីដែននេសាទគ្រប់ប្រភេទ ទោះជាបាន ឬ មិនទាន់បានធ្វើអត្តសញ្ញាណកម្មនិងមានផែនទីជាផ្លូវការក៏ដោយ ប៉ុន្តែមិនទាន់មានអាណត្តិកាន់កាប់ច្បាស់លាស់ រដ្ឋបាលជលផលត្រូវសហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ដើម្បីចុះស្រាវជ្រាវប្រមូលព័ត៌មានអំពីអត្តសញ្ញាណនៃដីដែននេសាទដែលត្រូវបានរំលោភនោះ។ ករណីនេះ រដ្ឋបាលជលផលត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុចទី ៤ នៃសារាចរលេខ ០២ សរ ដែលមានអភិបាលខេត្ត ក្រុង ទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតទាមទារដីរដ្ឋមកវិញរហូតដល់ដំណោះស្រាយត្រូវបានបញ្ចប់ អនុលោមតាមចំណុចទី ៣.១ ដល់ ចំណុចទី ៣.៧ នៃសារាចរនេះទើបរដ្ឋបាលជលផលចាត់ការអនុវត្តនីតិវិធីបន្តទៀតស្របតាមចំណុចទី ៣ នៃសារាចរនេះ ។

៤-ចំពោះការកាន់កាប់ដីរដ្ឋផ្សេងទៀតដោយខុសច្បាប់ ជាអាទិ៍ ដីកសិដ្ឋាន ដីស្ថានីយ៍ពិសោធន៍ស្រាវជ្រាវ ដីមណ្ឌលអភិវឌ្ឍន៍កសិកម្មដែលស្ថិតក្រោមការគ្រប់គ្រងរបស់បណ្តានាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និង មន្ទីរកសិកម្មខេត្ត ក្រុង ដែលមានតួនាទីជាអាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានត្រូវ :

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី ៣ នៃសារាចរលេខ ០២ សរ ក្នុងករណីដីរដ្ឋដែលត្រូវរំលោភនោះមានក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី ៤ នៃសារាចរលេខ ០២ សរ ក្នុងករណីដីរដ្ឋដែលត្រូវរំលោភនោះមិនទាន់បានចុះក្នុងបញ្ជីទ្រព្យរដ្ឋ

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី ២ នៃសារាចរលេខ ០២ សរ ក្នុងករណីដីរដ្ឋដែលត្រូវរំលោភនោះ

បានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចហើយ ។

៥-អាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើសម្រង់ករណីចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង ប្រមូលផ្តុំឯកសារគ្រប់គ្រាន់តាមករណីនីមួយៗ ហើយត្រូវចូលរួមតាមដានតាមមុខការគ្រប់ករណីនៃការដោះស្រាយបណ្តឹងតវ៉ា ។

៦-អាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើរបាយការណ៍តាមករណីនីមួយៗ និង ជាប្រចាំ ស្តីពីលទ្ធផលនៃដំណោះស្រាយបណ្តឹងតវ៉ាលើការកាន់កាប់ដីរដ្ឋដោយខុសច្បាប់មកក្រសួងតាមឋានានុក្រម ។ ក្នុងករណីអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់សុខចិត្តប្រគល់ដីរដ្ឋនោះមកវិញតាមនីតិវិធី អាជ្ញាធរកាន់កាប់ដីរដ្ឋនោះត្រូវចាត់វិធានការបន្ទាន់ថែរក្សាការពារឱ្យបានគង់វង្ស និង ស្នើសុំការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចាត់វិធានការអនុវត្តបន្ត ។

៧-ក្នុងករណីដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទបានទទួលសំណុំឯកសារពាក់ព័ន្ធនឹងការប្រគល់ដីជូនរដ្ឋវិញ នាយកដ្ឋានផែនការ ស្ថិតិ មានភារកិច្ចធ្វើជាចំណុចកណ្តាលទទួល-ផ្តល់ព័ត៌មាន និង រាល់ឯកសារស្តីពីការប្រគល់ដីរដ្ឋ និង ការទាមទារដីរដ្ឋនានាមកវិញ ។ ក្នុងករណីពិនិត្យឃើញថា ប្រភេទដីដែលបានប្រគល់ ឬ ទាមទារនោះស្ថិតនៅក្រោមសមត្ថកិច្ចអង្គភាពជំនាញជាក់លាក់ណាមួយក្រោមឱវាទក្រសួង នាយកដ្ឋានផែនការ ស្ថិតិ ត្រូវចាត់វិធានការដើម្បីក្រសួងបញ្ជូនសំណុំឯកសារនោះជាបន្ទាន់ទៅអង្គភាពជំនាញដើម្បីមុខការបន្ត ។

ក្នុងករណីដីដែលបានប្រគល់ ឬ ត្រូវទាមទារមកវិញនោះមិនទាន់មានភាពច្បាស់លាស់ស្ថិតក្រោមសមត្ថកិច្ចនៃអង្គភាពណានោះ នាយកដ្ឋានផែនការ ស្ថិតិ ត្រូវសហការសម្របសម្រួលជាមួយបណ្តាអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ដើម្បីពិនិត្យ និង សិក្សាលើរាល់សំណុំឯកសារទាំងអស់ ព្រមទាំងកំណត់អំពីទីតាំង អត្តសញ្ញាណនៃដីរដ្ឋដែលបានប្រគល់ ឬ ត្រូវទាមទារមកវិញនោះ ។ អង្គភាពពាក់ព័ន្ធត្រូវចាត់តាំងមន្ត្រីជំនាញដើម្បីចូលរួមពិនិត្យ និង សិក្សាតាមការស្នើសុំរបស់នាយកដ្ឋានផែនការ ស្ថិតិ ។ ក្រោយពីពិនិត្យឃើញប្រភេទដីរដ្ឋដែលត្រូវទទួល ឬ ទាមទារមកវិញនោះស្ថិតនៅក្រោមសមត្ថកិច្ចអង្គភាពណាហើយ នាយកដ្ឋានផែនការ ស្ថិតិ ត្រូវចាត់វិធានការដើម្បីក្រសួងបញ្ជូនសំណុំឯកសារទៅអង្គភាពពាក់ព័ន្ធនោះដើម្បីមុខការបន្ត ។

ក្រោយពេលទទួលបានព័ត៌មាន ឬ ឯកសារស្តីពីការប្រគល់ដីរដ្ឋមកវិញនោះ អង្គភាពជំនាញមានសមត្ថកិច្ចត្រូវចាត់វិធានការគ្រប់គ្រង ថែរក្សាដីរដ្ឋនោះឱ្យបានគង់វង្ស ។

៨-បន្ទាប់ពីទទួលបានសំណុំឯកសារគ្រប់គ្រាន់ហើយ អង្គភាពពាក់ព័ន្ធដែលជាអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចាត់ការដោយពិនិត្យកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទដីរដ្ឋដែលបានទទួលមកវិញ ដើម្បីអនុវត្តតាមនីតិវិធីដូចខាងក្រោម :

ក-ក្នុងករណីដីរដ្ឋដែលបានទទួលមកតាមនីតិវិធីណាមួយនោះ អាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋ ត្រូវទំនាក់

ទំនងធ្វើការចុះបញ្ជីតាមប្រភេទដីរដ្ឋនីមួយៗនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង ភូមិបាលស្រុក ខណ្ឌ សាមី ក្នុងសៀវភៅគោលបញ្ជីដីធ្លីអនុលោមតាមនីតិវិធីនៃច្បាប់ និង សារាចរលេខ ០២ សរ ជាធរមាន ។

ខ-ក្នុងករណីដីរដ្ឋដែលបានប្រគល់មកអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋតាមរូបភាពណាមួយនោះគឺជាដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដីព្រៃលិចទឹក ដីព្រៃកោងកាង ឬ ដីដែននេសាទគ្រប់ប្រភេទ ដែលមានអាណត្តិកាន់កាប់ច្បាស់លាស់ អាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋ ត្រូវធ្វើសំណើតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្នើទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បីធ្វើការចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋតាមនីតិវិធីនៃច្បាប់ជាធរមាន ។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-ក្រសួងបរិស្ថាន

-គ្រប់សាលាខេត្ត ក្រុង

-ឯកសារ-កាលប្បវត្តិ